# ជំពូកទី៤ ការធ្វើតេស្តប៉ារ៉ាម៉ែត្រព្យាករណ៍

## Estimator's Testing

រៀបរៀងនិងបង្រៀនដោយបណ្ឌិត ង៉ាន់ ស៊ុនដេត

សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# ធ្វើតេស្ត មេគុណ $\beta$

- មេគុណប៉ាន់ស្មានដែលយើងរកឃើញកំណត់ដោយ $\beta_1$, $\beta_1 = \frac{\sum(X_i - \bar{X})(Y_i - \bar{Y})}{\sum(X_i - \bar{X})^2}$
- គោលបំណងធ្វើតេស្តគឺចង់ដឹងថា តើវាមានកម្រិតជឿជាក់ដូចម្តេច?
- តាមធម្មតាកម្រិតជឿជាក់គឺជាហានិភ័យ $\alpha = \{10\%, 5\%, 1\%\}$ ។
- មេគុណប៉ាន់ស្មាន $\beta$ ដែលបានកំណត់ អាចជាវិជ្ជមាន ឬ អវិជ្ជមាន អាស្រ័យតាមការគណនាទិន្នន័យពីគំរូសំណាកនៃការអង្កេត។
- ការធ្វើតេស្ត ត្រូវគណនា Ratio Student, កំណត់ដោយ t-stat=t*
- $t - stat = t^* = \frac{|\beta_1|}{sd_{\beta_1}}$ ដែល $sd_{\beta_1}$ ជាគម្លាតស្តង់ដានៃមេគុណប៉ាន់ស្មាន

# ធ្វើតេស្ត មេគុណ $\beta$

- ករណីទី១ ការធ្វើតេស្តលើមេគុណប៉ាន់ស្មានដែលបានរកឃើញ
- មុនដំបូងគណនាវ៉ារ្យង់នៃផលបូកការេសំណល់ $var(RSS) = \frac{\sum e_i^2}{n-2},\ i = 1,2,\dots,n$
- បន្ទាប់មកគណនាវ៉ារ្យង់មេគុណ $var\left(sd_{\beta_1}\right) = (sd_{\beta_1})^2 = \frac{var(RSS)}{var(X)} = \frac{\sum e_i^2}{(n-2)\sum(X_i-\bar{X})^2}$
- យើងបាន $sd_{\beta_1} = \sqrt{(sd_{\beta_1})^2} = \sqrt{\frac{\sum e_i^2}{(n-2)\sum(X_i-\bar{X})^2}}$

# ធ្វើតេស្ត មេគុណ $\beta$

- កំណត់សម្មតិកម្ម
  - ❖ Null Hypothesis Ho: $\beta_1 = 0$
  - ❖ Alternative Hypothesis H1: $\beta_1 \neq 0$

- កំណត់ ratio $t^*_{\beta_1} = \frac{|\beta_1|}{sd_{\beta_1}}$ ទៅតាមច្បាប់ Student ត្រង់កម្រិតសេរីនៃចំនួនគំរូអង្កេតដែលកំណត់ដោយ $n-2$ ។
  - ❖ បើ $t^*_{\beta_1} > t^{\frac{\alpha\%}{2}}_{n-2}$ នោះយើងអាចបដិសេធសម្មតិកម្ម Ho និងមេគុណ $\beta_1$ មានអត្ថន័យស្ថិតិត្រង់ហានិភ័យ $\alpha\%$ ដែលគេឲ្យ។
  - ❖ បើ $t^*_{\beta_1} < t^{\frac{\alpha\%}{2}}_{n-2}$ នោះយើងទទួលយកសម្មតិកម្ម Ho និងមេគុណ $\beta_1$ គ្មានអត្ថន័យស្ថិតិត្រង់ហានិភ័យ $\alpha\%$ ដែលគេឲ្យ។

# ធ្វើតេស្ត មេគុណ $\beta$

- ករណីទី២ ប្រៀបធៀបមេគុណប៉ាន់ស្មាន $\widehat{\beta_1}$ដែលរកឃើញ និងមេគុណ$\beta_1$ដែលគេឲ្យ
- កំណត់សម្មតិកម្ម
  - ❖ Hypothesis H0: $\widehat{\beta_1} = \beta_1$
  - ❖ Hypothesis H1: $\widehat{\beta_1} \neq \beta_1$
- កំណត់តម្លៃ $t - stat = t^* = \frac{|\widehat{\beta_1} - \beta_1|}{sd_{\beta_1}}$

# ធ្វើតេស្ត មេគុណ $\beta$

❖បើ $t^*_{\beta_1} > t^{\frac{\alpha\%}{2}}_{n-2}$ នោះយើងអាចបដិសេធសម្មតិកម្ម Ho និងមេគុណ $\widehat{\beta_1} \neq \beta_1$ មានអត្ថន័យស្ថិតិត្រង់ហានិភ័យ $\alpha\%$ ដែលគេឲ្យ។

❖បើ $t^*_{\beta_1} < t^{\frac{\alpha\%}{2}}_{n-2}$ នោះយើងទទួលយកសម្មតិកម្ម Ho និងមេគុណ $\widehat{\beta_1} = \beta_1$ គ្មានអត្ថន័យស្ថិតិត្រង់ហានិភ័យ $\alpha\%$ ដែលគេឲ្យ។

- ករណីទី៣ ប្រៀបធៀបមេគុណនៃសមីការប៉ាន់ស្មានពីរដែលមានស្ថានភាពដូចគ្នា
  1. គេឲ្យសមីការប៉ាន់ស្មានទី១ $y_i = \alpha_0 + \alpha_1 x_i , i = 1,2, \dots , n$
  2. គេឲ្យសមីការប៉ាន់ស្មានទី២ $y_i = \beta_0 + \beta_1 x_i , i = 1,2, \dots , n$
- កំណត់សម្មតិកម្មនៃការប្រៀបធៀប

# ធ្វើតេស្ត មេគុណ $\beta$

❖Hypothesis Ho: $\hat{\alpha}_1 = \hat{\beta}_1$ Ho: $\mathrm{d} = \hat{\alpha}_1 - \hat{\beta}_1 = 0$

❖Hypothesis H1: $\hat{\alpha}_1 \neq \hat{\beta}_1$ H1: $\mathrm{d} = \hat{\alpha}_1 - \hat{\beta}_1 \neq 0$

- យើងបានផលធៀប $\frac{(\hat{\alpha}_1-\hat{\beta}_1)-(\alpha_1-\beta_1)}{sd_{(\hat{\alpha}_1-\hat{\beta}_1)}}$ គឺជាច្បាប់ Student នៃកម្រិតសេរី $n_1+n_2-4$
- យើងមាន $sd_d^2 = sd_{\hat{\alpha}_1}^2 + sd_{\hat{\beta}_1}^2$, ពីព្រោះ $cov(\hat{\alpha}_1, \hat{\beta}_1) = 0$
- ដូច្នេះយើងបាន $t^* = \frac{\hat{d}}{sd_{\hat{d}}} = \frac{|(\hat{\alpha}_1-\hat{\beta}_1)-(\alpha_1-\beta_1)|}{\sqrt{sd_{\hat{\alpha}_1}^2+s\ {}_{\hat{\beta}_1}^2}}$

# ធ្វើតេស្ត មេគុណ $\beta$

❖ បើ $t^* > t^{\frac{\alpha\%}{2}}_{n_1+n_2-4}$ នោះយើងអាចបដិសេធសម្មតិកម្ម Ho និងមេគុណ $\hat{\alpha}_1 \neq \hat{\beta}_1$ មានអត្ថន័យស្ថិតិត្រង់ហានិភ័យ $\alpha\%$ ដែលគេឲ្យ។

❖ បើ $t^* < t^{\frac{\alpha\%}{2}}_{n_1+n_2-4}$ នោះយើងទទួលយកសម្មតិកម្ម Ho និងមេគុណ $\hat{\alpha}_1 = \hat{\beta}_1$ គ្មានអត្ថន័យស្ថិតិត្រង់ហានិភ័យ $\alpha\%$ ដែលគេឲ្យ។

- ឧទាហរណ៍១៖ កៀ្សតវិទូបានសិក្សាដីផ៥ក្បាលលើទិន្នផលពោត $y_i$ មានការពាក់ព័ន្ធជាមួយអត្រានៃជាតិរ៉ែ bauxite $x_i$ ដែលមានក្នុងដី។ លទ្ធផលបានបង្ហាញតាមសមីការវិភាគខាងក្រោម៖

$$y_i = 132.80 - 1.1x_i + e_i, \; i = 1,2,\dots 85$$

(4.3) (10.2)

(.): ratio of Student, $\sum e^2 = 6\,234.32$

សំណួរ ក. ធ្វើតេស្តមេគុណ $x_i$ ត្រង់ហានិភ័យ១%? ខ. ធ្វើតេស្តប្រៀបធៀបមេគុណដែលគេឲ្យ -1។

# ចម្លើយឧទាហរណ៍១

- សំណួរទី១

  សម្មតិកម្ម $H0\colon \hat{\beta}_1 = 0, H1\colon \hat{\beta}_1 \neq 0$

  យើងបាន $t^*_{\hat{\beta}_1} = \frac{\hat{\beta}_1}{sd\hat{\ }_1} = 10.2 > t^{\frac{5\%}{2}}_{85-2} = 1.96$ ដូច្នេះគឺបដិសេធសម្មតិកម្ម $H0$, មេគុណ $\hat{\beta}_1 \neq 0$ និងមានអត្ថន័យស្ថិតិត្រង់ហានិភ័យ ៥%។

- សំណួរទី២ តើមេគុណ $\hat{\beta}_1 = -1.1$ អាចបដិសេធមេគុណសម្មតិកម្ម $\beta = -1$ បានឬទេ?

  សម្មតិកម្ម $H0\colon \hat{\beta}_1 = -1, H1\colon \hat{\beta}_1 < -1$

  យើងមាន $\frac{\hat{\beta}_1}{sd\hat{\beta}_1} = 10.2 \Rightarrow sd\hat{\beta}_1 = \frac{\hat{\beta}_1}{10.2} = \frac{|-1.1|}{10.2} = 0.1078$

  $\frac{|-1.1-(-1)|}{0.1078} = \frac{|-0.10|}{0.1078} = 0.92 < t^{\frac{10\%}{2}}_{83} = 1.644$ ទទួលយក $H0$ មេគុណ $\hat{\beta}_1$គ្មានអត្ថន័យស្ថិតិខុសពី – 1បានទេ។ ចន្លោះអង្កត់ជឿជាក់វាគឺ $\beta_1 \in [\hat{\beta}_1 \mp 1.96sd\hat{\beta}_1]$=> $\beta_1$ ∈[-1.31, -0.89] ។

# ធ្វើតេស្តប្រៀបធៀបមេគុណ $\beta$ នៃពីរសមីការព្យាករណ៍

- ឧទាហរណ៍2 អ្នកសេដ្ឋកិច្ចជំនាញខាងធនធានមនុស្សបានពិនិត្យឃើញមានភាពជាប់ពាក់ព័ន្ធរវាងលាភការនិងការសិក្សា(តាមទ្រឹស្តីធនធានមនុស្ស)។ ក្នុងកិច្ចការស្រាវជ្រាវ អ្នកអង្កេតបានយកសំណាកបុរស៤០នាក់ និងនារី២៥នាក់ដែលមានអាយុប្រហាក់ប្រហែលគ្នា។ ចំណូលគិតជាពាន់ដុល្លាកំណត់ដោយ $y_i$ និងចំនួនឆ្នាំសិក្សាកំណត់ដោយ $x_i$ ។ លទ្ធផលបង្ហាញតទៅនេះ ៖

សម្រាប់បុរស $y_i = 18.60 + 1.8x_i + e_i, i = 1,2,\dots,40 \;\; n_1 = 40$

(9.3) (5.2)

(.)=*ratio Student*, $R^2 = 0.42$

សម្រាប់នារី $y_i = 14.50 + 0.7x_i + e_i, i = 1,2,\dots,25 \;\; n_2 = 25$

(12.8) (2.5)

(.)=*ratio Student*, $R^2 = 0.22$

ចូរប្រៀបធៀបចំណូលប្រចាំឆ្នាំរវាងបុរសនិងនារី តើមានភាពផ្សេងគ្នាដែរឬទេ?

# ធ្វើតេស្តប្រៀបធៀបមេគុណ $\beta$ នៃពីរសមីការព្យាករណ៍

- ដំបូងធ្វើតេស្តអត្ថន័យមេគុណសមីការនីមួយៗជាមុនសិន៖

$$t^{*}_{\hat{\beta}h} = \frac{\hat{\beta}_{1h}}{sd\hat{\beta}_{1h}} = 5.2 > t^{\frac{2\%}{2}}_{40-2} = 2.326$$

$$t^{*}_{\hat{\beta}f} = \frac{\hat{\beta}_{1f}}{sd\hat{\beta}_{1f}} = 2.5 > t^{\frac{5\%}{2}}_{25-2} = 2.06$$

- គម្លាតគំរូនៃមេគុណនីមួយៗ

$$sd\hat{\beta}_{1h} = \frac{\hat{\beta}_{1h}}{5.2} = \frac{1.8}{5.2} = 0.34 \text{ និង } sd\hat{\beta}_{1f} = \frac{\hat{\beta}_{1f}}{2.5} = \frac{0.7}{2.5} = 0.28$$

- មេគុណប៉ាន់ស្មាននៃសមីការទាំងពីរមានអត្ថន័យខុសពី 0 ត្រង់ហានិភ័យ២%និង៥%។ គួរកត់សម្គាល់ដែរថា មេគុណចំណូលរបស់ស្ត្រីមានតម្លៃតូចនិងមានអត្ថន័យត្រង់ហានិភ័យ៥%។
- ធ្វើតេស្តពីភាពមិនប្រក្រតីនេះ

សម្មតិកម្ម Ho: $\hat{\beta}_{1h} = \hat{\beta}_{1f}$ Ho: d= $\hat{\beta}_{1h} - \hat{\beta}_{1f} = 0$

សម្មតិកម្ម H1: $\hat{\beta}_{1h} \neq \hat{\beta}_{1f}$ H1: d=$\hat{\beta}_{1h} - \hat{\beta}_{1f} \neq 0$

# ធ្វើតេស្តប្រៀបធៀបមេគុណ $\beta$ នៃពីរសមីការព្យាករណ៍

- ផលធៀប $\frac{(\hat{\beta}_{1h}-\hat{\beta}_{1f})-(\beta_{1h}-\beta_{1f})}{\widehat{sd}_{\hat{\beta}_{1h}-\hat{\beta}_{1f}}}$ គឺជាច្បាប់ Student ក្នុងកម្រិតសេរី $n_1+n_2-4$ ។

$\widehat{sd}^2_{\hat{d}} = \widehat{sd}^2_{\hat{\beta}_{1h}} + \widehat{sd}^2_{\hat{\beta}_{1f}}, \hat{d} = \hat{\beta}_{1h} - \hat{\beta}_{1f}$ ហើយតាមសម្មតិកម្ម Ho កន្សោមផលធៀបសរសេរ

$t^* = \frac{(1.8-0.7)-(0-0)}{\sqrt{0.34^2+0.28^2}} = 2.49 > t^{\frac{5\%}{2}}_{65-4} = 1.96$ អាចបដិសេធ Ho និងមានអត្ថន័យស្ថិតិត្រង់ហានិភ័យ ២,៥%ដែលអាចសន្និដ្ឋានបានថាមេគុណព្យាការណ៍ប្រាក់ចំណូលរបស់បុរស $\hat{\beta}_{1h} \neq \hat{\beta}_{1f}$ ដែលជាមេគុណព្យាការណ៍ប្រាក់ចំណូលរបស់នារីពិតប្រាកដ អាចនិយាយបានថាការកំណត់ប្រាក់ឈ្នួលមានភាពរើសអើងរវាងនារីនិងងបុរស។

# ការធ្វើតេស្តមេគុណ និងអថេរចង្អុលបង្ហាញ

ឧទាហរណ៍ទី៣ ការអង្កេតមួយលើការចំណាយទិញសម្លៀកបំពាក់ប្រចាំឆ្នាំ មានការជាប់ពាក់ព័ន្ធនឹងចំណូលប្រចាំឆ្នាំរបស់20គ្រួសារ បន្ទាប់ពីពួកគេបានចូលកំសាន្តពិពណ៌លក់សម្លៀកបំពាក់រួចមក។ ការអង្កេតនៃការទិញចែកចេញពីរប្រភេទ ហើយការចំណាយគិតជា $ ៖

- អ្នកទីក្រុង = 1, បើរស់នៅតំបន់ទីក្រុង(City zone), 0 បើរស់នៅផ្សេងពីនេះ(If otherwise)(អ្នករស់នៅតាមតំបន់ជនបទឬជាប់ជាយក្រុង)។

សំណួរ

ក. សរសេរសមីការចំណាយក្នុងការទិញសម្លៀកបំពាក់ប្រចាំឆ្នាំរបស់គ្រួសារទូទៅ(ទាំងអ្នកទីក្រុង និងជនបទ)និងបកស្រាយអត្ថន័យ។

ខ. ធ្វើតេស្តមេគុណរបស់អថេរនីមួយៗផ្តើមចេញត្រង់ហានិភ័យ ៥%។

គ. សរសេរសមីការចំណាយទិញសម្លៀកបំពាក់តាមតំបន់នីមួយៗ។

- ទិន្នន័យអង្កេតចំនួន20គ្រួសារ, ចំណូលចំណាយប្រចាំឆ្នាំវាស់ជាដុល្លា$UD។

| ob | Cloth Exp in $ | Income in $ | City |
|---|---|---|---|
| 1 | 3937 | 61089 | 1 |
| 2 | 3000 | 31965 | 0 |
| 3 | 2026 | 24926 | 0 |
| 4 | 3018 | 36014 | 0 |
| 5 | 3205 | 35939 | 1 |
| 6 | 2552 | 28926 | 0 |
| 7 | 2192 | 22016 | 1 |
| 8 | 2205 | 25120 | 0 |
| 9 | 2557 | 32100 | 1 |
| 10 | 3025 | 41200 | 1 |
| 11 | 2055 | 26000 | 0 |
| 12 | 2575 | 41700 | 1 |
| 13 | 2190 | 26690 | 0 |
| 14 | 3507 | 44760 | 1 |
| 15 | 1980 | 23790 | 0 |
| 16 | 2090 | 65090 | 1 |
| 17 | 3208 | 45095 | 0 |
| 18 | 4019 | 54769 | 1 |
| 19 | 2010 | 43795 | 1 |
| 20 | 3205 | 50190 | 1 |

# ការធ្វើតេស្តមេគុណ និងអថេរចង្អុលបង្ហាញ

ក. សមីការចំណាយលើសម្លៀកបំពាក់ $\boldsymbol{Cloth}_i = \beta_0 + \beta_1 \boldsymbol{Income}_i + \beta_2 \boldsymbol{City} + u_i, i = 1,2, \dots, n.$

បកស្រាយអត្ថន័យសមីការវិភាគ៖ សមីការមានអថេរពន្យល់ពីចំពោះការប្រើប្រាស់សម្លៀកបំពាក់។ បើដេរីវេទី១ធៀបនឹង $Income_i$ និង $City$ យើងបានរៀងគ្នា៖

$(\boldsymbol{Cloth}_{Income})' = \beta_1$ និង $(\boldsymbol{Cloth}_{City})' = \beta_2$។

- បើ $(\boldsymbol{Cloth}_{Inco}\ \ )' = \beta_1 > 0 \Rightarrow$ ការប្រើប្រាស់សម្លៀកបំពាក់ជាអនុគមន៍កើននៃចំណូលប្រចាំឆ្នាំមានន័យថាកាលណាចំណូលកើន១ដុល្លា នាំឲ្យការប្រើប្រាស់សម្លៀកបំពាក់កើន $\beta_1$ឯកតា (Marginal propensity of consumption)។ ផ្ទុយមកវិញមានការថយចុះ។
- បើ $(\boldsymbol{Cloth}_{City})' = \beta_2 > 0 \Rightarrow$ ការប្រើប្រាស់សម្លៀកបំពាក់ជាអនុគមន៍កើននៃចំនួនប្រជាជនរស់ក្នុងទីក្រុង។ ផ្ទុយមកវិញមានការថយចុះ ប៉ុន្តែការណ៏ជាក់ស្តែងអាចមិនកើតមាន។

# ការធ្វើតេស្តមេគុណ និងអថេរចង្អុលបង្ហាញ

តារាងវិភាគទិន្នន័យតាម Excel ៖

| | | | | | | |
|---|---|---|---|---|---|---|
| SUMMARY OUTPUT | | | | | | |
| Regression Statistics | | | | | | |
| Multiple R | 0.583529 | | | | | |
| R Square | 0.340506 | | | | | |
| Adjusted R Square | 0.262918 | | | | | |
| Standard Error | 558.0877 | | | | | |
| Observations | 20 | | | | | |
| ANOVA | | | | | | |
| | df | SS | MS | F | Significance F | |
| Regression | 2 | 2733800.975 | 1366900 | 4.38866 | 0.029059941 | |
| Residual | 17 | 5294852.225 | 311461.9 | | | |
| Total | 19 | 8028653.2 | | | | |
| | Coefficients | Standard Error | t Stat | P-value | Lower 95% | Upper 95% |
| Intercept | 1607.362 | 418.5920984 | 3.839924 | 0.001312 | 724.2098623 | 2490.51412 |
| Income | 0.028927 | 0.012568055 | 2.301656 | 0.034274 | 0.002411058 | 0.05544362 |
| City | 35.45667 | 313.4086279 | 0.113132 | 0.911251 | -625.7777314 | 696.691079 |

# ការធ្វើតេស្តមេគុណ និងអថេរចង្អុលបង្ហាញ

ខ. សមីការព្យាករណ៍ការប្រើប្រាស់សម្លៀកបំពាក់ទូទៅ និងធ្វើតេស្តមេគុណ ៖

$$\widehat{Clothing}_i = 1607.362 + 0.029\,(Income_i) + 35.456(City_i) + e_i, i = 1,2,\dots,20.$$

(3.839) (2.301) (0.113)

*n = 20, R-square = 0.262, (.) = t-student*

*t-student* អានក្នុងតារាង *Normal ត្រង់កម្រិតសេរី n-k-1=20-2-1=17,* $t_{(20;2)}^{5\%/2} = 2.110$

មានតែមេគុណ ***Income*** ទេដែលមានអត្ថន័យស្ថិតិគ្រប់គ្រាន់ខុសពី 0 ត្រង់ហានិភ័យ៥%។ ចំណែកមេគុណ ***City*** គ្មានអត្ថន័យស្ថិតិគ្រប់គ្រាន់ខុសពី 0 ត្រង់ហានិភ័យ៥%ទេ។

# ការធ្វើតេស្តមេគុណ និងអថេរចង្អុលបង្ហាញ

គ. សរសេរសមីការនៃការប្រើប្រាស់សម្លៀកបំពាក់តាមតំបន់នីមួយៗ ៖

បើ City = 1, គឺជាប្រជាជនរស់នៅតំបន់ទីក្រុង យើងបាន៖

$$\widehat{\boldsymbol{Clothing}}_i = 1607.362 + 0.029\,(\boldsymbol{Income}_i) + 35.456 \times (1) + e_i, i = 1,2,\dots,20 \rightarrow$$

$$\Rightarrow \widehat{\boldsymbol{Clothing}}_i = \mathbf{1642.818} + 0.029\,(\boldsymbol{Income}_i) + e_i, i = 1,2,\dots,20.$$

បើ City = 0, គឺជាប្រជាជនរស់នៅតំបន់ជនបទឬតំបន់ជាប់ជាយក្រុង យើងបាន៖

$$\widehat{\boldsymbol{Clothing}}_i = 1607.362 + 0.029\,(\boldsymbol{Income}_i) + 35.456 \times (0) + e_i, i = 1,2,\dots,20 \rightarrow$$

$$\Rightarrow \widehat{\boldsymbol{Clothing}}_i = \mathbf{1607.362} + 0.029\,(\boldsymbol{Income}_i) + e_i, i = 1,2,\dots,20.$$

ជាសន្និដ្ឋាន អ្នកទីក្រុងចំណាយក្នុងការប្រើប្រាស់សម្លៀកបំពាក់ $35.456 លើសអ្នករស់នៅតាមតំបន់ជនបទឬតំបន់ជាប់ជាយក្រុង។

# ការធ្វើតេស្តមេគុណ និងអថេរចង្អុលបង្ហាញ

- ឧទាហរណ៍ទី៤ ការសិក្សាមួយលើតម្រូវការទូរស័ព្ទចល័ត(Y) ក្នុងចំណោមមនុស្ស១០០នាក់ និងចំណូលមធ្យម (X$)ក្នុងម្នាក់ៗនៃ១០០នាក់ នៅក្នុងប្រទេសសចំនួន៣៤។ សមីការវិភាគដែលទទួលបានពីទិន្នន័យអង្កេតនៅឆ្នាំ ២០០៦កំណត់ដោយ៖

$$\hat{Y}_i = 14.4673 + 0.0022X_i$$
$$(6.1523) \quad (0.00032), \quad R^2 = 0.6023$$
$$n = 34, \quad (.) = se$$

**សំណួរ** ចូរធ្វើការបកស្រាយសមីការវិភាគនេះ។

ជាដំបូងត្រូវកំណត់សម្មតិកម្ម៖ $H_0: \hat{\beta}_1 = 0, H_1: \hat{\beta}_1 \neq 0$

$\mathrm{t-stat}\hat{\beta}_1;\ t^* = \frac{0.0022}{0.00032} = 6.875 > t_{(34;1)}^{1\%/2} = 2.457$ មានតម្លៃធំគ្រប់គ្រាន់ក្នុងការបដិសេធសម្មតិកម្ម $H_0$ និង មានអត្ថន័យស្ថិតិខុសពី0 ត្រង់ហានិភ័យ១%។ មេគុណ $\hat{\beta}_1$ ក្នុងពេលនេះមានន័យថា ក្នុងចំណូល $1000 ជាមធ្យមចំនួនអតិថិជនទិញទូរស័ព្ទចល័តកើនឡើងប្រមាណ ២,២នាក់ក្នុង១០០នាក់។ ករណីចំនួនថេរស្មើនឹង ១៤,៤៧ ទោះបីគ្មានចំណូល $0 ជាមធ្យមអាចមានទូរស័ព្ទចល័ត ១៤នាក់ក្នុង១០០នាក់។ តែមានករណីក្នុងប្រទេសខ្លះអាចមិនពិតដែរ ពីព្រោះតម្លៃមេគុណកំណត់ទំនាក់ទំនង $R^2 = 0.6023$ តូច មានន័យថាសមីការវិភាគអាចពន្យល់បានជាង៦០%។

# ការធ្វើតេស្តមេគុណ និងអថេរចង្អុលបង្ហាញ

- ឧទាហរណ៍ទី៥ ការសិក្សាមួយលើតម្រូវការកុំព្យូទ័រផ្ទាល់ខ្លួនក្នុងចំណោមមនុស្ស១០០នាក់ និងចំណូលមធ្យម(X$)ក្នុងម្នាក់ៗនៃ១០០នាក់ នៅក្នុងប្រទេសសចំនួន៣៤។ សមីការវិភាគដែលទទួលបានពីទិន្នន័យអង្កេតនៅឆ្នាំ២០០៦កំណត់ដោយៈ

$$\widehat{PC}_i = -6.5833 + 0.0018X_i$$
$$(2.7437) \quad (0.00014), \quad R^2 = 0.8290$$
$$n = 34, \quad (.) = se$$

សំណួរ ចូរធ្វើការបកស្រាយសមីការវិភាគនេះ។

ជាដំបូងត្រូវកំណត់សម្មតិកម្មៈ $H_0$: $\hat{\beta}_1 = 0, H_1$: $\hat{\beta}_1 \neq 0$

$\text{t} - \text{stat}\hat{\beta}_1$; $t^* = \frac{0.0018}{0.00014} = 12.857 > t_{(34;1)}^{1\%/2} = 2.457$ មានតម្លៃធំគ្រប់គ្រាន់ក្នុងការបដិសេធសម្មតិកម្ម $H_0$ និងមានអត្ថន័យស្ថិតិខុសពី0 ត្រង់ហានិភ័យ១%។ មេគុណ $\hat{\beta}_1$ ក្នុងពេលនេះមានន័យថា ក្នុងចំណូល $1000 ជាមធ្យមចំនួនអតិថិជនទិញកុំព្យូទ័រផ្ទាល់ខ្លួនកើនឡើងប្រមាណ ២នាក់ក្នុង១០០នាក់។ ករណីចំនួនថេរស្មើនឹង −6.58 ក្នុងករណីជាក់ស្តែងមិនមានអត្ថន័យពន្យល់ណាមួយជាក់លាក់ទេ។ ទោះយ៉ាងណា តម្លៃមេគុណកំណត់ទំនាក់ទំនង $R^2$= 0.829 ធំគ្រប់គ្រាន់ មានន័យថាសមីការវិភាគអាចពន្យល់បានជាង ៨២%។

# ខ្សែកោង Phillips: Inflation rate and Unemployment rate

- នៅក្នុងទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចខ្សែកោង Phillips (Phillips Curve) មានភាពល្បីល្បាញលើការសិក្សាទំនាក់ទំនងរវាងអត្រាអតិផរណា(Inflation rate) និងភាពឥតការធ្វើ(Unemployment rate)។ Phillips បានប្រើទិន្នន័យអត្រាភាគរយបំរែបំរួលនៃការផ្លាស់ប្តូរប្រាក់ឈ្នួល(Y) និងអត្រាភាពឥតការងារធ្វើ(X) នៅចក្រភពអង់គ្លេសចន្លោះឆ្នាំ 1861-1957។ វាមានព័ត៌មានមិនស្មើរភាពគ្នាក្នុងការឆ្លើយតបនឹងការប្រែប្រួលអត្រាប្រាក់ឈ្នួលដល់កម្រិតអត្រាគ្មានការងារធ្វើ៖ ប្រាក់ឈ្នួលកើនឡើងលឿនសម្រាប់ការប្រែប្រួល១ឯកតានៅក្នុងភាពគ្មានការធ្វើប្រសិនបើអត្រាគ្មានការងារធ្វើទាបជាង$U^N$ នេះហៅថា*អត្រាធម្មជាតិនៃភាពគ្មានការងារធ្វើ* ដោយអ្នកសេដ្ឋកិច្ច(កំណត់អត្រាភាពគ្មានការងារធ្វើដោយរក្សាអតិផរណានៅថេរ[wage])។
- បន្ទាប់មកអត្រាអអតិផរណាធ្លាក់ចុះយឺតៗ ចំពោះការផ្លាស់ប្តូរដែលស្មើគ្នានៅពេលអត្រាគ្មានការងារធ្វើគឺខ្ពស់ជាងអត្រាធម្មជាតិ $U^N$ បង្ហាញពីអាស៊ីមតូតជាន់ខ្ពស់ ឬ $-\beta_0$ សម្រាប់ការផ្លាស់ប្តូរប្រាក់ឈ្នួល។
- យក $\pi_t$ តាងអត្រាអតិផរណានៅរយៈពេល $t$ ដែលទិផរណាថ្លៃវាស់ដោយសន្ទស្សន៍តំណាងថ្លៃ(CPI)
- យក $UN_t$ តាងអត្រាភាពគ្មានការងារធ្វើនៅរយៈពេល $t$

# ខ្សែកោង Phillips: Inflation rate and Unemployment rate

- យើងបានសមីការខ្សែកោង Phillips កំណត់ដោយយកន្សោមខាងក្រោមនេះ៖

  $\pi_t - \pi_t^e = \beta_1(UN_t - U^N) + u_t$ (១) where $u_t$ is stochastic error term.

  ដែល $\pi_t$ = អត្រាអតិផរណាជាក់ស្តែងនៅរយៈពេល $t$

  $\pi_t^e$ = រំពឹងទុកអត្រាអតិផរណានៅរយៈពេល $t$, ការរំពឹងទុកត្រូវបានបង្កើតឡើងនៅឆ្នាំ $t-1$.

  $UN_t$ = អត្រាគ្មានការងារធ្វើជាក់ស្តែងទូទៅនៅរយៈពេល $t$

  $U^N$ = អត្រាធម្មជាតិនៃភាពគ្មានការងារធ្វើ

- ដោយសារតែ $\pi_t^e$ មិនត្រូវបានគេសង្កេតឃើញដោយផ្ទាល់ទេដែលជាចំណុចចាប់ផ្តើមមួយអាចធ្វើឲ្យការសន្និដ្ឋានបានថា $\pi_t^e = \pi_{t-1}$ នោះគឺអត្រាអតិផរណាដែលរំពឹងទុកនៅឆ្នាំនេះគឺជាអត្រាអតិផរណាដែលបានយកមកកាលពីឆ្នាំមុន។ ជាការពិតការសន្មតដែលស្មុគស្មាញជាងនេះអំពីការបង្កើតការរំពឹងទុកអាចត្រូវបានធ្វើឡើង។
- ពន្លាតសមីការ(១)៖ $\pi_t - \pi_t^e = -\beta_1 U^N + \beta_1 UN_t + u_t$ ដោយយក $\beta_0 = -\beta_1 U^N \Rightarrow U^N = \frac{\beta_0}{-\beta_1}$
- សមីការទៅជា $\pi_t - \pi_t^e = \beta_0 + \beta_1 UN_t + u_t$
- សញ្ញារបស់ $\beta_0$ រំពឹងថាវិជ្ជមាន។ សញ្ញារបស់ $\beta_1$ ជាអវិជ្ជមាន តើមានមូលហេតុអ្វី?

# ខ្សែកោង Phillips: Inflation rate and Unemployment rate

- ចៃដន្យទំនាក់ទំនង Phillips ដែលបានផ្តល់ឲ្យនៅក្នុងសមីការ (១) ត្រូវបានគេស្គាល់នៅក្នុងទ្រឹស្តីសេដ្ឋកិច្ចថា«ខ្សែកោង Phillips ដែលបានកែប្រែឬ ការរំពឹងទុកបានបង្កើនខ្សែកោង Phillips (ដើម្បីបង្ហាញថា $\pi_{t-1}$ តំណាងឲ្យអតិផរណាដែលរំពឹងទុក) ឬខ្សែកោងបង្កើនល្បឿន Phillips(ដើម្បីបង្ហាញថាអត្រាគ្មានការងារធ្វើទាបនាំឱ្យមានការកើនឡើងនៃអត្រាអតិផរណាហេតុដូចនេះ ហើយនាំឲ្យមានការបង្កើនកម្រិតតម្លៃ)» ។



# សិក្សាឧទាហរណ៍ខ្សែកោង Phillips: Inflation rate and Unemployment rate

| year | INFLRATE | UNRATE | year | INFLRATE | UNRATE |
|---|---|---|---|---|---|
| 1960 | 1.718 | 5.5 | 1984 | 4.317 | 7.5 |
| 1961 | 1.014 | 6.7 | 1985 | 3.561 | 7.2 |
| 1962 | 1.003 | 5.5 | 1986 | 1.859 | 7 |
| 1963 | 1.325 | 5.7 | 1987 | 3.65 | 6.2 |
| 1964 | 1.307 | 5.2 | 1988 | 4.137 | 5.5 |
| 1965 | 1.613 | 4.5 | 1989 | 4.818 | 5.3 |
| 1966 | 2.857 | 3.8 | 1990 | 5.403 | 5.6 |
| 1967 | 3.086 | 3.8 | 1991 | 4.208 | 6.8 |
| 1968 | 4.192 | 3.6 | 1992 | 3.01 | 7.5 |
| 1969 | 5.46 | 3.5 | 1993 | 2.994 | 6.9 |
| 1970 | 5.722 | 4.9 | 1994 | 2.561 | 6.1 |
| 1971 | 4.381 | 5.9 | 1995 | 2.834 | 5.6 |
| 1972 | 3.21 | 5.6 | 1996 | 2.953 | 5.4 |
| 1973 | 6.22 | 4.9 | 1997 | 2.294 | 4.9 |
| 1974 | 11.036 | 5.6 | 1998 | 1.558 | 4.5 |
| 1975 | 9.128 | 8.5 | 1999 | 2.209 | 4.2 |
| 1976 | 5.762 | 7.7 | 2000 | 3.361 | 4 |
| 1977 | 6.503 | 7.1 | 2001 | 2.846 | 4.7 |
| 1978 | 7.591 | 6.1 | 2002 | 1.581 | 5.8 |
| 1979 | 11.35 | 5.8 | 2003 | 2.279 | 6 |
| 1980 | 13.499 | 7.1 | 2004 | 2.663 | 5.5 |
| 1981 | 10.316 | 7.6 | 2005 | 3.388 | 5.1 |
| 1982 | 6.161 | 9.7 | 2006 | 3.226 | 4.6 |
| 1983 | 3.212 | 9.6 | | | |

# ខ្សែកោង Phillips: Inflation rate and Unemployment rate

- គំរូលីនេអ៊ែរ យើងបានសមីការវិភាគ៖

$$\widehat{(\pi_t - \pi_{t-1})} = 3.7844 - 0.6385UN_t$$

(4.1912) (-4.2755)

n = 46, R-square = 0.2935, (.)=t-statistics

$$U^N = \frac{3.7844}{0.6385} = 5.927 = \text{natural unemployment rate.}$$

- គំរូច្រាស យើងបានសមីការ៖

$$\widehat{(\pi_t - \pi_{t-1})} = -3.0683 + 17.2075\left(\frac{1}{UN_t}\right)$$

(-3.1634) (3.2886)

n = 46, R-square = 0.1973, (.)=t-statistics

- Inflation curve

